នស/រកត/០១១៨/០៧៨

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** តម្លើងថ្នាក់ និងឋានន្តរស័ក្តិតាមសញ្ញាបត្រ ដល់មន្ត្រីរាជការ ០៧ រូប នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **សុភ ផេង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ២- | ឯកឧត្តម | **ស្វាយ សុវណ្ណរិទ្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៣- | លោកជំទាវ | **គង់ វណ្ណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៤- | លោក | **នេង វណ្ណរិទ្ធ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៥- ឯកឧត្តម **ឈឹម យីស៊ាង** ពីរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៦- ឯកឧត្តម **រោង ឈង** ពីរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

៧- ឯកឧត្តម **ថោ គឿន** ពីរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

**មាត្រា ២ ៖** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០១១៨.០៧៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៨

លេខ: ១០៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**